ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ នៃអនុក្រឹត្យ លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបន្ថែមសមាជិកគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានសម្បទានដីសង្គមកិច្ចចំណុះអគ្គនាយកដ្ឋានលំនៅឋាន
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

## សម្រេច

**មាត្រា មួយ.-**

កែសម្រួលមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ដូចតទៅ÷

**មាត្រា ២១.-ថ្មី**

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| - អគ្គមេបញ្ជាការរងនិងជានាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តគោលដៅ | សមាជិក |
| - ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |

- ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកមជ្ឈមណ្ឌលបោសសំអាតមីន សមាជិក
- ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍
- ប្រធាននាយកដ្ឋានសម្បទានដីសង្គមកិច្ច នៃអគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខាធិការ

ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ជាសេនាធិការ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា ២២.-ថ្មី**

អគ្គនាយកដ្ឋានលំនៅឋានដែលជាសេនាធិការរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- លើកគោលការណ៍ត្រួតពិនិត្យ តាមដានការផ្តល់សម្បទានដីសង្គមកិច្ច និងកែសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិនានាជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- លើកគោលការណ៍លុបចោលការសម្រេច ឬកែសម្រួលផែនការប្រើប្រាស់ និងបែងចែកដីនៅថ្នាក់រាជធានី ខេត្ត ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- ធ្វើជាជំនួយការបច្ចេកទេសក្នុងការធ្វើអត្តសញ្ញាណកម្មដីសម្បទានសង្គមកិច្ច ការធ្វើសនិទានកម្មដីទំនេរជាមួយនឹងតម្រូវការដីសម្បទាន
- រៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដាក់ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- លើកផែនការសកម្មភាពការងារ របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- អនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

- ជំរុញការតាមដានវាយតម្លៃលើការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ អំពីលទ្ធផលការងារ ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ច ថ្នាក់ជាតិ
- រៀបចំ និងសម្រួលកិច្ចប្រជុំរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និង
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។

**មាត្រា ២៣.-ថ្មី**

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់រាជធានី ខេត្ត ជាស្ថាប័នកំណត់គោលនយោបាយសម្បទានដីសង្គមកិច្ចថ្នាក់រាជធានី ខេត្ត។

គណៈកម្មាធិការនេះ មានមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- រៀបចំផែនការប្រើប្រាស់ដី និងលើកសំណើធ្វើចំណាត់ថ្នាក់ទីតាំងដីសម្បទានសង្គមកិច្ចប្រសិនបើចាំបាច់
- ធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ នូវទិន្នន័យដីទំនេររបស់រដ្ឋក្នុងរាជធានី ខេត្ត
- កំណត់មុខសញ្ញាអ្នកទទួលដី និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំរាល់មុខសញ្ញាអ្នកទទួលដី
- សិក្សាកំណត់ទីតាំងដី ដើម្បីអនុវត្តផែនការសម្បទានដីសង្គមកិច្ចប្រចាំឆ្នាំ
- ធ្វើសនិទានកម្មដីទំនេរឱ្យស្របទៅនឹងសេចក្តីត្រូវការរបស់មុខសញ្ញាអ្នកទទួលដីនៅគ្រប់ក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្ត
- ពិនិត្យ និងវាយតម្លៃផែនការប្រើប្រាស់ដី និងផែនការសម្បទានដីសង្គមកិច្ចដែលស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់
- សម្រេចយល់ព្រមលើផែនការប្រើប្រាស់ដី និងការបែងចែកដីរដ្ឋនៅថ្នាក់រាជធានី ខេត្ត
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំផែនការប្រើប្រាស់ដី និងធ្វើចំណាត់ថ្នាក់ដី
- សម្រេចយល់ព្រម ឬបដិសេធ ឬកែសម្រួលផែនការសម្បទានដីសង្គមកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានស្នើឡើង
- បញ្ជូនផែនការសម្បទានដីសង្គមកិច្ច និងសេចក្តីសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ច ទៅថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់មួយចំនួនដូចជា បណ្តាញគមនាគមន៍ អណ្តូងទឹក ស្រះសហគមន៍ មណ្ឌលឬប៉ុស្តិ៍សុខភាព និងសាលារៀនជាដើម
- ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសម្បទានដីសង្គមកិច្ចនៅតាមរាជធានី ខេត្ត និង
- សហការជាមួយអាជ្ញាធរមីន ចំពោះទីតាំងដែលអាចមានសំណល់ជាតិផ្ទុះ។

**មាត្រាពីរ.-**

អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៩ ស្ដីពីការបន្ថែមសមាជិកគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ៨ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**និងជាប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ**

**ជា សុផារ៉ា**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ